


៩.១

# សិទ្ធិមានវត្តមាននៅពេលសវនាការ

## និយមន័យ



សិទ្ធិមានវត្តមាននៅពេលសវនាការ មានន័យថាជនគ្រប់រូបដែលត្រូវបានចោទប្រកាន់ពីបទព្រហ្មទណ្ឌមានសិទ្ធិមានវត្តមាននៅអំឡុងពេលទាំងមូលនៃសវនាការរបស់ខ្លួន។ ការមានវត្តមាននៅពេលសវនាការរបស់ខ្លួនអនុញ្ញាតឱ្យជនជាប់ចោទដឹងឮពីសំណុំរឿងដែលចោទប្រកាន់មកលើខ្លួន ការដាក់បន្ទុករបស់អយ្យការ និងការមានវត្តមានមេធាវីការពារក្តី។ សិទ្ធិនេះក៏អាចឱ្យជនជាប់ចោទស្តាប់ដោយខ្លួនឯង ជាពិសេសដោយការផ្តល់សក្ខីកម្មនៅពេលសវនាការរបស់ខ្លួនប្រសិនបើពួកគេចង់ ដោយមិនមានការបង្ខិតបង្ខំ។

ដើម្បីធានាថា សិទ្ធិមានវត្តមាននៅពេលសវនាការត្រូវបានការពារ អាជ្ញាធរមានតួនាទីក្នុងការប្រាប់ជនជាប់ចោទ និងមេធាវីការពារក្តីរបស់ពួកគេ ដោយបញ្ជាក់ប្រាប់ពួកគេឱ្យបានគ្រប់គ្រាន់ពីពេលវេលា កាលបរិច្ឆេទ និងទីកន្លែងនៃការជំនុំជម្រះឱ្យបានមុន។ អាជ្ញាធរក៏ត្រូវតែចៀសវាងការទប់ស្កាត់ខុស ឬមិនរាប់បញ្ចូលវត្តមានរបស់ជនជាប់ចោទ។



## ក្របខ័ណ្ឌច្បាប់

### ច្បាប់អន្តរជាតិ

សិទ្ធិមានវត្តមាននៅពេលសវនាការត្រូវបានការពារជាក់លាក់ដោយមាត្រា ១៤ (៣)(ឃ) នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ “ក្នុងការសម្រេចសេចក្តីចោទប្រកាន់ពីបទព្រហ្មទណ្ឌណាមួយប្រឆាំងមកលើខ្លួន ជនគ្រប់រូបមានសិទ្ធិទទួលបាន៖ ការជំនុំជម្រះដោយមានវត្តមានរបស់ខ្លួន និងការពារខ្លួនដោយផ្ទាល់ខ្លួនឯង ឬតាមរយៈជំនួយការច្បាប់តាមការជ្រើសរើសរបស់ខ្លួន...។”



### ច្បាប់អន្តរជាតិ




សិទ្ធិមានវត្តមាននៅពេលសវនាការត្រូវបានការពារយ៉ាងច្បាស់ដោយមាត្រា ៣០០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា “ជនជាប់ចោទត្រូវចូលបង្ហាញខ្លួននៅពេលសវនាការរបស់តុលាការដោយផ្ទាល់ [...]” និងមានបញ្ញត្តិនៅក្នុងមាត្រាមួយចំនួនទៀតនៃនីតិវិធីព្រហ្មទណ្ឌ។ សិទ្ធិនេះក៏មានចែងនៅក្នុងមាត្រា ៥១ នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជនផងដែរ។

# សារសំខាន់

សិទ្ធិមានវត្តមាននៅពេលសវនាការ និងការជំនុំជម្រះដោយផ្ទាល់ គឺជាធាតុផ្សំសំខាន់នៃសិទ្ធិក្នុងការការពារខ្លួនដោយផ្ទាល់ ឬតាមរយៈមេធាវីការពារក្តី និងចាំបាច់ណាស់ក្នុងការធានាឱ្យមានការជំនុំជម្រះដោយយុត្តិធម៌។

ការមានវត្តមានរបស់ជនជាប់ចោទអនុញ្ញាតឱ្យពួកគេបានដឹងឮ និងតទល់ទៅនឹងភស្តុតាងដែលប្រឆាំងនឹងខ្លួន និងបង្ហាញការការពាររបស់ខ្លួន ដោយការហៅសាក្សី និងការធ្វើសក្ខីកម្មនៅក្នុងសវនាការ ប្រសិនជាពួកគេចង់។ ហេតុដូចនេះ ដំណើរការសវនាការដោយអវត្តមានរបស់ជនជាប់ចោទ គឺបំពានទៅលើសិទ្ធិជាមូលដ្ឋានរបស់ជនជាប់ចោទក្នុងការការពារខ្លួនឯង និងនាំឱ្យសវនាការមិនស្របច្បាប់។

# ដែនកំណត់

សិទ្ធិមានវត្តមាននៅពេលសវនាការ គឺមិនមែនសិទ្ធិដាច់ខាតទេ។ សវនាការដោយគ្មានវត្តមានរបស់ជនជាប់ចោទ គឺត្រូវបានលើកលែងនៅក្នុងកាលៈទេសៈមួយចំនួន ប្រសិនបើផលប្រយោជន៍នៃការគ្រប់គ្រងយុត្តិធម៌ដ៏ត្រឹមត្រូវតម្រូវ។ នៅក្នុងកាលៈទេសៈតែមួយគត់ដែលសិទ្ធិមានវត្តមាននៅពេលសវនាការមិនអាចត្រូវបានធ្វើបដិប្បញ្ញត្តិ ឬត្រូវបានរឹតត្បិតជាបណ្តោះអាសន្នៈ

ប្រសិនបើជនជាប់ចោទបដិសេធសិទ្ធិមានវត្តមានរបស់ខ្លួន។ ការបដិសេធនេះត្រូវធ្វើជាលាយល័ក្ខអក្សរ និងដោយមានមធ្យោបាយការពារគ្រប់គ្រាន់។

ប្រសិនបើតុលាការយល់ឃើញថា វត្តមានរបស់ជនជាប់ចោទពិតជារំខានដល់ដំណើរការនីតិវិធីតុលាការដាក់ស្តែងមែន។ ក្នុងករណីនេះ តុលាការអាចអនុញ្ញាតឱ្យជនជាប់ចោទចេញពីបន្ទប់សវនាការជាបណ្តោះអាសន្នបាន។ ទោះយ៉ាងណាក៏ដោយ វិធានការចាំបាច់ទាំងអស់ ដើម្បីធានាថាសិទ្ធិរបស់ជនជាប់ចោទក្នុងការការពារក្តីត្រូវតែអនុវត្តជាពិសេសវត្តមានមេធាវីរបស់ជនជាប់ចោទនៅក្នុងសវនាការ ដូច្នេះមេធាវីអាចបន្តការការពារកូនក្តីរបស់ពួកគេបាន។

ប្រសិនបើមិនអាចរកអាសយដ្ឋានរបស់ជនជាប់ចោទឃើញ ឬជនជាប់ចោទបដិសេធក្នុងការចូលខ្លួនក្នុងសវនាការ ទោះបីជាបានទទួលការជូនដំណឹងគ្រប់គ្រាន់ហើយក៏ដោយ។

នៅក្នុងកាលៈទេសៈដែលជនជាប់ចោទលះបង់សិទ្ធិរបស់ខ្លួន ឬមិនអាចចូលសវនាការបាន ទោះបីជាមានការជូនដំណឹងគ្រប់គ្រាន់រួចហើយក៏ដោយ សវនាការអាចធ្វើឡើងដោយកំបាំងមុខមានន័យថា ធ្វើឡើងដោយមិនមានវត្តមានរបស់ជនជាប់ចោទ។ តុលាការត្រូវពិចារណាមើលថាតើអ្វីជាស្ថានភាពដែលបង្ហាញថា ជនជាប់ចោទអវត្តមានពីការចូលខ្លួនមកក្នុងសវនាការនៅមុនពេលចាប់ផ្តើមសវនាការ។

ខែកញ្ញា ឆ្នាំ២០២២

មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា Cambodian Center for Human Rights

Sweden Sverige

People Change the World Diakonia

CC BY NC SA